ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

សេចក្តីជូនព័ត៌មាន
ស្តីពីការប្រគល់ត្រឡប់មកវិញនូវវត្ថុសិល្បៈខ្មែរចំនួន១៨ ពីទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមជម្រាបជូនសាធារណជនមេត្តាជ្រាបអំពីការប្រគល់ត្រឡប់មកកម្ពុជាវិញនូវវត្ថុសិល្បៈខ្មែរចំនួន១៨ រូប/បំណែក ដែលបានស្វែងរកឃើញនៅទីក្រុងឡុងដ៍ ដោយអង្គភាពសិល្បៈនិងវត្ថុបុរាណនៃនគរបាលទីក្រុងឡុងដ៍ (Metropolitan Police Service) ក្រោមការគាំទ្រពីក្រុមការងារប្រយុទ្ធប្រឆាំងបទល្មើសលើបេតិកភណ្ឌនៃអង្គការសន្តិសុខនិងសហប្រតិបត្តិការនៅអឺរ៉ុប(OSCE)។ វត្ថុទាំងនេះត្រូវបានប្រគល់ជាផ្លូវការនៅថ្ងៃនេះ ជូនស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងឡុងដ៍ ហើយក្រសួងនឹងចាត់ចែងបញ្ជូនមកកម្ពុជា នាពេលខាងមុខ។

វត្ថុសិល្បៈទាំងនេះត្រូវបានស្វែងរកឃើញកាលពីខែវិច្ឆិកា ឆ្នាំ២០២៥ ហើយត្រូវបានកំណត់អត្តសញ្ញាណថាមានប្រភពដើមមកពីប្រទេសកម្ពុជា។ បន្ទាប់មក នៅក្នុងខែកញ្ញា ឆ្នាំ២០២៦ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានដាក់សំណើជាផ្លូវការដើម្បីទាមទារឱ្យប្រគល់វត្ថុទាំងនេះត្រឡប់មកកម្ពុជាវិញ។ វត្ថុទាំងនេះរួមមាន៖ រូបចម្លាក់សាងពីថ្ម វត្ថុធ្វើពីសំរិទ្ធសម្រាប់ប្រើប្រាស់ក្នុងកិច្ចពិធី និងបំណែកគ្រឿងអលង្ការ ដែលមានអាយុកាលប្រមាណពីសតវត្សទី១០ ដល់សតវត្សទី១៣។ ក្នុងចំណោមវត្ថុទាំងនេះ មានព្រះសិរ្សបដិមាសាងពីថ្មកក់ ក្នុងរចនាបថបាពួន រាងពាក់កណ្តាលទីពីរនៃសតវត្សទី១១ និងព្រះសិរ្សបដិមា ក្នុងរចនាបថបាយ័ន ចុងសតវត្សទី១២។ ក្រៅពីនេះ ក៏មានកណ្តឹងពុទ្ធសាសនា ដែលមានដងកាន់រាងវជ្រ ទេពរាំលើបល្ល័ង្ក (យោគីនីរាំ) គ្រឿងលម្អមានបន្ទោង ព្រមទាំងចង្កៀងសំរិទ្ធមួយ ដែលធ្លាប់ប្រើប្រាស់ក្នុងកិច្ចពិធី។ ជារួម វត្ថុទាំងនេះឆ្លុះបញ្ចាំងពីស្នាដៃសិល្បៈ ប្រពៃណី ជំនឿសាសនា និងជីវភាពវប្បធម៌និងអារ្យធម៌ខ្មែរដែលបានឆ្លងកាត់ជាច្រើនសតវត្សមកហើយ។

សម្រាប់ប្រជាជនកម្ពុជា វត្ថុសិល្បៈទាំងនេះមានអត្ថន័យលើសពីតម្លៃសិល្បៈទៅទៀត។ ផ្អែកតាមជំនឿ និងប្រពៃណីខ្មែរ បដិមាដែលត្រូវបានធ្វើពិធីអភិសេករួច គឺជាបដិមាមានជីវិតនិងព្រលឹង និងជាទីស្ថាននៃអាទិទេព។ នៅពេលវត្ថុសក្ការៈទាំងនេះត្រូវបានយកចេញពីទីតាំងដើម សហគមន៍បានបាត់បង់មិនត្រឹមតែមរតកជារូបីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបាត់បង់ចំណងដ៏សំខាន់នៃប្រវត្តិសាស្ត្រ ជំនឿ ប្រពៃណី ទំនៀមទម្លាប់ និងការចងចាំរួមរបស់សហគមន៍ផងដែរ។

បន្ទាប់ពីវត្ថុទាំងនេះត្រូវបានបញ្ជូនត្រឡប់មកកម្ពុជាវិញ មន្ត្រីជំនាញក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងសារមន្ទីរជាតិកម្ពុជា នឹងធ្វើការសិក្សាស្រាវជ្រាវលើវត្ថុទាំងនេះ និងប្រៀបធៀបជាមួយលទ្ធផលស្រាវជ្រាវនៅទីតាំងជាក់ស្តែង កំណត់ត្រាទីតាំងបុរាណវិទ្យា និងសក្ខីកម្មផ្ទាល់ដែលមាន។ ការងារនេះនឹងរួមចំណែក

ជួយឱ្យកាន់តែយល់ច្បាស់អំពីប្រវត្តិ និងប្រភពដើមរបស់វត្ថុទាំងនេះ ព្រមទាំងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់កម្ពុជាក្នុងការកំណត់អត្តសញ្ញាណ និងស្វែងរកសម្បត្តិវប្បធម៌ដែលត្រូវបាននាំចេញពីទឹកដីកម្ពុជាដោយខុសច្បាប់។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះមន្ត្រីនៃអង្គភាពសិល្បៈ និងវត្ថុបុរាណនៃនគរបាលទីក្រុងឡុងដ៍ និងក្រុមការងារប្រយុទ្ធប្រឆាំងបទល្មើសលើបេតិកភណ្ឌ ដែលដឹកនាំដោយអង្គការ ដើម្បីសន្តិសុខនិងសហប្រតិបត្តិការនៅអឺរ៉ុប (OSCE) ចំពោះកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរសម្បត្តិវប្បធម៌ដោយខុសច្បាប់។ ក្រសួងក៏សូមថ្លែងអំណរគុណចំពោះលោក Bradley J. Gordon និងលោកស្រី Melina Antoniadis ទីប្រឹក្សាផ្នែកច្បាប់របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ចំពោះការខិតខំបំពេញការងារប្រកបដោយការយកចិត្តទុកដាក់ និងការប្តេជ្ញាចិត្តខ្ពស់ ក្នុងការជួយជ្រោមជ្រែងឱ្យមានការប្រគល់វត្ថុទាំងនេះត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ។

ការប្រគល់វត្ថុសិល្បៈទាំង១៨នេះត្រឡប់មកវិញ គឺជាសមិទ្ធផលដ៏សំខាន់មួយទៀតនៃកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់កម្ពុជាក្នុងការស្វែងរក និងនាំយកមកវិញនូវសម្បត្តិវប្បធម៌ដែលបានបាត់បង់ពីមាតុភូមិ។ កម្ពុជានៅតែបន្តប្តេជ្ញាចិត្តក្នុងការទាមទារឱ្យប្រគល់ត្រឡប់មកវិញនូវសម្បត្តិវប្បធម៌ដែលត្រូវបាននាំចេញពីទឹកដីកម្ពុជាដោយខុសច្បាប់ និងសូមស្វាគមន៍ចំពោះកិច្ចសហប្រតិបត្តិការជាបន្តបន្ទាប់ពីរដ្ឋាភិបាលស្ថាប័នអនុវត្តច្បាប់ សារមន្ទីរ អ្នកស្រាវជ្រាវ និងអ្នកប្រមូលវត្ថុសិល្បៈឯកជននានា។

ថ្ងៃសុក្រ ៤រោច ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៦

វត្ថុសិល្បៈខ្មែរ - Khmer Cultural Objects



ព្រះសិរ្សព្រះពុទ្ធរូប
ថ្មភក់
សម័យអង្គរ, រចនាបថបាយ័ន្ត ចុងស.វ.ទី១២-ដើមស.វ.១៣គ.ស.

Head of Buddha
Sandstone
Angkor period, Bayon style, late 12th-early 13th Century



ទេពរាំលើបល្ល័ង្ក (យោគីនីរាំ)
សំរិទ្ធ
សម័យអង្គរ, រចនាបថបាយ័ន្ត ចុងស.វ.ទី១២-ដើម១៣គ.ស.

Dancing figures on pedestal
Bronze
Angkor period, Bayon style late12th-early 13th Century



គ្រឿងលម្អមានបន្ទោង
ប្រាក់លាបទឹកមាសជាំត្បូង
សម័យអង្គរ, រចនាបថបាភួន, ស.វ.ទី១១ គ.ស.

Decorative plaque with pendant
Silver gilded with stone inlay
Angkor period, Bayon style late12th-early 13th Century



កណ្តឹងវជ្រ
សំរិទ្ធ
សម័យអង្គរ, រចនាបថបាយ័ន្ត ចុងស.វ.ទី១២-ដើម១៣គ.ស.

Buddhist bell (ghanta) with a vajra handle
Bronze
Angkor period, Bayon style late12th-early 13th Century